- សន្និធិគ្រាប់ពូជស្រូវស្រាលមិនប្រកាន់រដូវសរុបសមមូលចំនួន៣ ០០០(បីពាន់)តោន ដែលក្នុងនោះ២ ០០០(ពីរពាន់)តោន ជាគ្រាប់ពូជ និង១ ០០០(មួយពាន់)តោនផ្សេងទៀតជាសាច់ប្រាក់
- សន្និធិគ្រាប់ពូជបន្លែនិងគ្រាប់ពូជដំណាំរួមផ្សំផ្សេងៗទៀតសរុបសមមូលចំនួន៥០(ហាសិប) តោន ដែលក្នុងនោះ២៥(ម្ភៃប្រាំ)តោនជាគ្រាប់ពូជ និង២៥(ម្ភៃប្រាំ)តោនផ្សេងទៀតជាសាច់ប្រាក់។

ក្នុងករណីចាំបាច់ សន្និធិគ្រាប់ពូជបម្រុងដំបូងដែលបានកំណត់ខាងលើ អាចកែសម្រួលដោយនាយករដ្ឋមន្ត្រី តាមសំណើរបស់គណៈកម្មាធិការ **ម.ស.ម.ភ.**។

មាត្រា ១៣.-

សន្និធិគ្រាប់ពូជស្រូវស្រាលបម្រុងដំបូងចំនួន២ ០០០(ពីរពាន់)តោន និងសន្និធិគ្រាប់ពូជបន្លែនិងគ្រាប់ពូជដំណាំរួមផ្សំផ្សេងៗដំបូងចំនួន២៥(ម្ភៃប្រាំ)តោន ត្រូវគ្រប់គ្រងដោយអគ្គនាយកដ្ឋានកសិកម្មដែលជាសេនាធិការឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយផ្ទាល់ឬតាមរយៈកសិដ្ឋាន ស្ថានីយ ក្រុមហ៊ុនឯកជន និងសហគមន៍កសិករដែលផលិតគ្រាប់ពូជស្រូវ គ្រាប់ពូជបន្លែ និងគ្រាប់ពូជដំណាំរួមផ្សំផ្សេងៗ។

សន្និធិគ្រាប់ពូជស្រូវបម្រុងដំបូងជាសាច់ប្រាក់សមមូលនឹងគ្រាប់ពូជចំនួន១ ០០០(មួយពាន់)តោន និងសន្និធិគ្រាប់ពូជបន្លែនិងគ្រាប់ពូជដំណាំរួមផ្សំផ្សេងៗបម្រុងដំបូង ជាសាច់ប្រាក់សមមូលនឹងគ្រាប់ពូជចំនួន២៥(ម្ភៃប្រាំ) តោន ត្រូវគ្រប់គ្រងដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

គ្រាប់ពូជស្រូវស្រាល គ្រាប់ពូជបន្លែ និងគ្រាប់ពូជដំណាំរួមផ្សំផ្សេងៗទៀត ដែលរក្សាទុកជាសន្និធិគ្រាប់ពូជបម្រុងរបស់ **ម.ស.ម.ភ.** ត្រូវផលិតនិងរក្សាទុកយ៉ាងហ្មត់ចត់ ដោយអនុលោមតាមលក្ខខណ្ឌបច្ចេកទេសនៃការផលិតនិងការរក្សាទុកគ្រាប់ពូជ។

ផ្នែកទី២
គោលការណ៍ចាត់ចែង

មាត្រា ១៤.-

ក្នុងករណីមានតម្រូវការសង្គ្រោះបន្ទាន់ដោយសារគ្រោះមហន្តរាយឬគ្រោះអាសន្ននានា នាយករដ្ឋមន្ត្រីមានសិទ្ធិសម្រេចចាត់ចែងសន្និធិស្បៀងនិងគ្រាប់ពូជបម្រុង ជារូបវន្តឬជាសាច់ប្រាក់ ដើម្បីជួយប្រជាពលរដ្ឋរងគ្រោះ តាមតម្រូវការចាំបាច់និងបន្ទាន់ដូចខាងក្រោម៖

-តម្រូវការស្បៀងជាអង្ករលើសពី១ ០០០(មួយពាន់)តោន

-តម្រូវការគ្រាប់ពូជស្រូវលើសពី១០០(មួយរយ)តោន

-តម្រូវការគ្រាប់ពូជបន្លែនិងគ្រាប់ពូជដំណាំរួមផ្សំផ្សេងៗទៀត លើសពី១០(ដប់)តោន

-តម្រូវការដកប្រាក់ពីក្នុងគណនីតម្កល់មូលនិធិប្រាក់បម្រុង ដើម្បីទិញស្បៀងបន្ថែមលើសពី១ ០០០(មួយពាន់)តោន គ្រាប់ពូជស្រូវបន្ថែមលើសពី១០០(មួយរយ)តោន និងគ្រាប់ពូជបន្លែនិងគ្រាប់ពូជដំណាំរួមផ្សំផ្សេងៗទៀតបន្ថែមលើសពី១០(ដប់)តោន ។

មាត្រា ១៥.-

ក្នុងករណីមានតម្រូវការសង្គ្រោះបន្ទាន់ដោយសារគ្រោះមហន្តរាយឬគ្រោះអាសន្ននានា គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ មានសិទ្ធិសម្រេចចាត់ចែងសន្និធិស្បៀងនិងគ្រាប់ពូជបម្រុង ដើម្បីចែកចាយជូនប្រជាពលរដ្ឋរងគ្រោះ តាមតម្រូវការចាំបាច់និងបន្ទាន់ដូចខាងក្រោម៖

-តម្រូវការស្បៀងជាអង្ករតិចជាងឬស្មើ១ ០០០(មួយពាន់)តោន

-តម្រូវការគ្រាប់ពូជស្រូវក្នុងចន្លោះពី៣០(សាមសិប)តោន ទៅ១០០(មួយរយ)តោន

-តម្រូវការគ្រាប់ពូជបន្លែនិងគ្រាប់ពូជដំណាំរួមផ្សំផ្សេងៗទៀត ក្នុងចន្លោះពី ១(មួយ)តោន ទៅ១០(ដប់)តោន។

គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ អាចអនុវត្តសិទ្ធិសម្រេចចាត់ចែងសន្និធិស្បៀងនិងគ្រាប់ពូជបម្រុងនេះ បន្ទាប់ពីបានជូនដំណឹងជាមុនដល់នាយករដ្ឋមន្ត្រីនិងគណៈកម្មាធិការ **ប.ស.ប.ក.**។

មាត្រា ១៦.-

ក្នុងករណីមានតម្រូវការសង្គ្រោះបន្ទាន់ដោយសារគ្រោះមហន្តរាយឬគ្រោះអាសន្ននានា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសិទ្ធិសម្រេចចាត់ចែងសន្និធិគ្រាប់ពូជបម្រុង ដើម្បីចែកចាយជូនប្រជាពលរដ្ឋរងគ្រោះ តាមតម្រូវការចាំបាច់និងបន្ទាន់ដូចខាងក្រោម៖

-តម្រូវការគ្រាប់ពូជស្រូវតិចជាង៣០(សាមសិប)តោន

-តម្រូវការគ្រាប់ពូជបន្លែនិងគ្រាប់ពូជដំណាំរួមផ្សំផ្សេងៗទៀតតិចជាង ១(មួយ)តោន។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាចអនុវត្តសិទ្ធិសម្រេចចាត់ចែងសន្និធិគ្រាប់ពូជបម្រុងនេះ បន្ទាប់ពីបានជូនដំណឹងជាមុនដល់នាយករដ្ឋមន្ត្រី គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងគណៈកម្មាធិការ **ប.ស.ប.ក.**។

មាត្រា ១៧.-

ក្នុងករណីមានតម្រូវការសង្គ្រោះបន្ទាន់ដោយសារគ្រោះមហន្តរាយឬគ្រោះអាសន្ននានា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានសិទ្ធិសម្រេចដកប្រាក់ចេញពីគណនីតម្កល់មូលនិធិប្រាក់បម្រុង ដើម្បីទិញបន្ថែមសន្និធិស្បៀងនិងគ្រាប់ពូជបម្រុងតាមតម្រូវការចាំបាច់និងបន្ទាន់ដូចខាងក្រោម៖

-តម្រូវការទិញស្បៀងជាអង្ករតិចជាងឬស្មើ១ ០០០(មួយពាន់)តោន

-តម្រូវការទិញគ្រាប់ពូជស្រូវតិចជាងឬស្មើ១០០(មួយរយ)តោន

-តម្រូវការទិញគ្រាប់ពូជបន្លែនិងគ្រាប់ពូជដំណាំរួមផ្សំផ្សេងៗទៀតតិចជាងឬស្មើ១០(ដប់)តោន

-តម្រូវការចំណាយផ្សេងៗនៅក្នុងក្របខ័ណ្ឌ **ប.ស.ប.ក.**។

មាត្រា ១៨.-

ក្នុងករណីមានតម្រូវការសង្គ្រោះបន្ទាន់ដោយសារគ្រោះមហន្តរាយឬគ្រោះអាសន្ននានា គ្រាប់ពូជបម្រុងមានគុណភាព ត្រូវចែកចាយដោយឥតគិតថ្លៃជូនដល់ប្រជាកសិកររងគ្រោះ ដោយអនុលោមតាមបទបញ្ជារបស់នាយករដ្ឋមន្ត្រី។

ក្នុងករណីគ្មានបទបញ្ជាខាងលើ គ្រាប់ពូជបម្រុងមានគុណភាព ត្រូវលក់ដោយការបញ្ចុះថ្លៃ៥០% (ហាសិបភាគរយ)ធៀបនឹងតម្លៃទីផ្សារ តាមរយៈឧបត្ថម្ភធនជូនប្រជាកសិកររងគ្រោះ។ ចំណូលដែលប្រមូលបានពីការលក់គ្រាប់ពូជនេះ ត្រូវផ្ទេរដោយស្វ័យប្រវត្តិចូលក្នុងគណនីតម្កល់មូលនិធិប្រាក់បម្រុង។

មាត្រា ១៩.-

គណៈកម្មាធិការ **ប.ស.ប.ក.** ត្រួតពិនិត្យលើការបំពេញបន្ថែមសន្និធិស្បៀងនិងគ្រាប់ពូជបម្រុងនៅពេលដែលគុណភាពធ្លាក់ចុះទាបជាងនិយាមបច្ចេកទេស។ សន្និធិស្បៀងនិងគ្រាប់ពូជបម្រុងដែលត្រូវបានពិនិត្យឃើញថាថយឬបាត់បង់គុណភាព ត្រូវបញ្ចេញលក់ជាបន្ទាន់និងបំពេញបង្គ្រប់ជាថ្មី។

ចំណូលដែលប្រមូលបានពីការលក់ខាងលើ ត្រូវផ្ទេរដោយស្វ័យប្រវត្តិចូលក្នុងគណនីតម្កល់មូលនិធិប្រាក់បម្រុង។

មាត្រា ២០.-

ធនធានហិរញ្ញវត្ថុដែលផ្ដល់ដោយបណ្ដាដៃគូអភិវឌ្ឍ(រួមទាំងទីភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការអន្តរជាតិ)សង្គមស៊ីវិល វិស័យឯកជន និងសប្បុរសជនទាំងអស់ សម្រាប់ដំណើរការនៃ **ប.ស.ប.ក.** ត្រូវផ្ទេរដោយស្វ័យប្រវត្តិចូលក្នុងគណនីតម្កល់មូលនិធិប្រាក់បម្រុង។

ជំពូកទី៤

តួនាទីនិងភារកិច្ចរបស់ក្រសួង ស្ថាប័នអនុវត្តក្នុង ប.ស.ប.ក.

មាត្រា ២១.-

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ទីស្ដីការគណៈរដ្ឋមន្ត្រី ក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងពាណិជ្ជកម្ម ក្រសួងមហាផ្ទៃ គឺជាស្ថាប័នអនុវត្តនៅក្នុង **ប.ស.ប.ក.** ដែលត្រូវបំពេញតួនាទីនិងភារកិច្ចតាមសមត្ថកិច្ចរៀងៗខ្លួន។

មាត្រា ២២.-

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវប្រគល់តួនាទីជាអង្គភាពអនុវត្តក្នុង **ប.ស.ប.ក.** ដល់មន្ត្រីជាន់ខ្ពស់មួយរូប និងអង្គភាពពាក់ព័ន្ធក្រោមឱវាទរបស់ខ្លួនដើម្បីបំពេញភារកិច្ចបន្ថែមដូចខាងក្រោម៖

- គ្រប់គ្រងគណនីតម្កល់មូលនិធិប្រាក់បម្រុងសម្រាប់កិច្ចលទ្ធកម្ម ការថែរក្សា ការគ្រប់គ្រង ការដឹកជញ្ជូន និងប្រតិបត្តិការផ្សេងៗពាក់ព័ន្ធនឹងស្បៀងនិងគ្រាប់ពូជបម្រុងរបស់ **ប.ស.ប.ក.**

- តាមដាននិងត្រួតពិនិត្យការប្រើប្រាស់មូលនិធិប្រាក់បម្រុងក្នុងការទិញស្បៀងនិងគ្រាប់ពូជបម្រុង សម្រាប់ **ប.ស.ប.គ.**
- រៀបចំបម្រុងទុកថវិកាសម្រាប់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ក្រសួងពាណិជ្ជកម្ម និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងការថែរក្សាស្បៀងនិងគ្រាប់ពូជ ការផលិតគ្រាប់ពូជ ប្រតិបត្តិការសង្គ្រោះបន្ទាន់ និងប្រតិបត្តិការផ្សេងៗ ដែលទាក់ទងនឹង **ប.ស.ប.គ.**
- រៀបចំប្លុកសរុបថវិកាប្រចាំឆ្នាំរបស់ **ប.ស.ប.គ.** ដែលស្នើឡើងដោយក្រសួងពាណិជ្ជកម្មសម្រាប់ស្បៀង និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រាប់គ្រាប់ពូជ ដើម្បីស្នើសុំការអនុម័ត ដោយអនុលោមតាមបទប្បញ្ញត្តិនិងនីតិវិធីហិរញ្ញវត្ថុជាធរមាន
- គ្រប់គ្រងថវិកាទាំងអស់របស់ **ប.ស.ប.គ.**
- រៀបចំរបាយការណ៍ប្រចាំត្រីមាសនិងតាមការចាំបាច់ ជូននាយករដ្ឋមន្ត្រី និងជូនដំណឹងដល់ស្ថាប័នពាក់ព័ន្ធទាំងអស់ អំពីសភាពការណ៍ទូទៅរបស់ **ប.ស.ប.គ.**
- រៀបចំកិច្ចប្រជុំរបស់គណៈកម្មាធិការ **ប.ស.ប.គ.**។

មាត្រា ២៣.-

គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ត្រូវប្រគល់តួនាទីជាអង្គភាពអនុវត្តក្នុង **ប.ស.ប.គ.** ដល់អគ្គលេខាធិការដ្ឋានរបស់ខ្លួន ដែលមានអគ្គលេខាធិការរងមួយរូបទទួលបន្ទុក ដើម្បីបំពេញភារកិច្ចបន្ថែមដូចខាងក្រោម ៖

- គ្រប់គ្រងទិន្នន័យស្តីពីការប៉ាន់ប្រមាណនូវហានិភ័យនៃគ្រោះមហន្តរាយឬគ្រោះអាសន្ននានា
- រៀបចំនិងធ្វើការប៉ាន់ប្រមាណអំពីតម្រូវការស្បៀងនិងជួយធ្វើការប៉ាន់ប្រមាណគ្រាប់ពូជបន្ទាន់ នៅពេលមានគ្រោះមហន្តរាយឬគ្រោះអាសន្ននានា
- សម្របសម្រួលជាមួយស្ថាប័ននិងដៃគូអភិវឌ្ឍនានា ដើម្បីចែករំលែកព័ត៌មានស្តីពីតម្រូវការស្បៀងនិងគ្រាប់ពូជបន្ថែម
- រៀបចំរបាយការណ៍អំពីតម្រូវការស្បៀងបន្ទាន់ ជូននាយករដ្ឋមន្ត្រីដើម្បីជ្រាប ឬចាត់វិធានការចាំបាច់សម្រាប់ស្ថាប័នពាក់ព័ន្ធអនុវត្ត
- សម្របសម្រួលក្នុងការឆ្លើយតប នៅពេលមានគ្រោះមហន្តរាយឬគ្រោះអាសន្ននានាកើតឡើង
- សម្របសម្រួលក្នុងការកំណត់រកប្រជាពលរដ្ឋគោលដៅ ដែលទទួលរងផលប៉ះពាល់ដោយសារគ្រោះមហន្តរាយឬគ្រោះអាសន្ននានា
- សម្របសម្រួលការដឹកជញ្ជូននិងការដឹកនាំកិច្ចប្រតិបត្តិការចែកចាយស្បៀងជូនដល់ប្រជាពលរដ្ឋរងគ្រោះ

- សម្រួលការដឹកជញ្ជូន ការចែកចាយគ្រាប់ពូជ និងការលក់គ្រាប់ពូជតាមរយៈឧបត្ថម្ភធន ដល់ប្រជាកសិកររងគ្រោះ
- ប្រមូលនិងផ្ទេរប្រាក់ដែលទទួលបានពីការលក់គ្រាប់ពូជតាមរយៈឧបត្ថម្ភធន ទៅក្នុងគណនីតម្កល់មូលនិធិប្រាក់បម្រុង
- ប្រមូល ត្រួតពិនិត្យ និងគ្រប់គ្រងប្រព័ន្ធព័ត៌មានស្បៀងនិងគ្រាប់ពូជបម្រុងរបស់ **ម.ស.ម.ក.**
- ត្រួតពិនិត្យភស្តុភារ ស្បៀង និងគ្រាប់ពូជរបស់ **ម.ស.ម.ក.**។

មាត្រា ២៤.-

ទីស្តីការគណៈរដ្ឋមន្ត្រី បំពេញតួនាទីជាអង្គភាពអនុវត្តក្នុង **ម.ស.ម.ក.** តាមរយៈភារកិច្ចដូចខាងក្រោម៖

- ចូលរួមផ្សព្វផ្សាយសភាពការណ៍ពាក់ព័ន្ធនឹងគ្រោះមហន្តរាយឬគ្រោះអាសន្ននានា
- ចូលរួមកៀរគររកជំនួយពីគ្រប់មជ្ឈដ្ឋាន
- សម្របសម្រួលការងាររបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ។

មាត្រា ២៥.-

ក្រសួងមហាផ្ទៃ ចូលរួមបំពេញតួនាទីជាអង្គភាពអនុវត្តក្នុង **ម.ស.ម.ក.** តាមរយៈរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដោយបំពេញភារកិច្ចដូចខាងក្រោម៖

- សម្រួលការផ្តល់ព័ត៌មានស្តីពីស្ថានភាពទូទៅនៃតំបន់ដែលទទួលរងគ្រោះ ដោយសារគ្រោះមហន្តរាយឬគ្រោះអាសន្ននានា
- សម្រួលការប្រមូលទិន្នន័យនិងការប៉ាន់ប្រមាណអំពីហានិភ័យដែលកើតឡើងដោយសារគ្រោះមហន្តរាយឬគ្រោះអាសន្ននានា
- សម្រួលការប្រមូលទិន្នន័យនិងការប៉ាន់ប្រមាណអំពីតម្រូវការស្បៀងនិងគ្រាប់ពូជ
- ផ្តល់កិច្ចសហការដើម្បីកំណត់ប្រជាពលរដ្ឋគោលដៅ ដែលត្រូវទទួលការចែកចាយស្បៀង និងគ្រាប់ពូជ
- ផ្តល់កិច្ចសហការដើម្បីធ្វើការចែកចាយស្បៀងនិងគ្រាប់ពូជឬការលក់គ្រាប់ពូជតាមរយៈឧបត្ថម្ភធន
- ផ្តល់ការគាំទ្រនិងសហការត្រួតពិនិត្យលើការចែកចាយស្បៀងនិងគ្រាប់ពូជ។

មាត្រា ២៦.-

ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ បំពេញតួនាទីជាអង្គភាពអនុវត្តក្នុង **ម.ស.ម.ក.** តាមរយៈភារកិច្ចដូចខាងក្រោម៖

- រៀបចំនិងផ្សព្វផ្សាយឲ្យបានទៀងទាត់នូវព្រឹត្តិបត្រប្រចាំត្រីមាសស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ

- រៀបចំនិងផ្សព្វផ្សាយឱ្យបានទៀងទាត់នូវរបាយការណ៍តាមដាននិងវាយតម្លៃស្តីពីស្ថានភាពសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ
- ផ្តល់ព័ត៌មានស្តីពីស្ថានភាពសន្តិសុខស្បៀងនិងអាហារូបត្ថម្ភដល់ស្ថាប័នពាក់ព័ន្ធរបស់ **ប.ស.ប.ភ.** ដោយអនុលោមតាមអាណត្តិការងាររបស់ខ្លួន
- ផ្តល់ការគាំទ្រនិងសម្របសម្រួលក្នុងការតាមដាននិងវាយតម្លៃ ដើម្បីធ្វើឱ្យ **ប.ស.ប.ភ.** ធានានូវតម្លាភាពនិងគណនេយ្យភាព។

មាត្រា ២៧.-

ក្រសួងពាណិជ្ជកម្ម ត្រូវប្រគល់តួនាទីជាអង្គភាពអនុវត្តក្នុង **ប.ស.ប.ភ.** ដល់ក្រុមហ៊ុនហ្គ្រីនត្រេដ ដើម្បីបំពេញភារកិច្ចបន្ថែមដូចខាងក្រោម ៖

- រៀបចំកិច្ចលទ្ធកម្មសន្និធិស្បៀងបម្រុងជាអង្ករបស់ **ប.ស.ប.ភ.**
- ជ្រើសរើសនិងចុះកិច្ចសន្យាសហការជាដៃគូជាមួយក្រុមហ៊ុនឯកជន នៅក្នុង**ប.ស.ប.ភ.** ដោយធានាបាននូវបរិមាណ គុណភាព និងការដឹកជញ្ជូនស្បៀងទាន់ពេលវេលា ទៅកាន់គោលដៅចែកចាយ
- ធានាដឹកជញ្ជូនស្បៀងបម្រុងទាន់ពេលវេលាទៅកាន់គោលដៅចែកចាយនៅក្នុង **ប.ស.ប.ភ.**
- គ្រប់គ្រងបញ្ជីសារពើភណ្ឌនៃសន្និធិស្បៀងបម្រុងទាំងអស់ ដែលមាននៅក្នុងឃ្លាំងផ្ទាល់របស់ក្រុមហ៊ុនហ្គ្រីនត្រេដនិងឃ្លាំងរបស់ក្រុមហ៊ុនឯកជនជាដៃគូ
- គ្រប់គ្រងនិងត្រួតពិនិត្យសន្និធិស្បៀងបម្រុង ដើម្បីធានាបរិមាណនិងគុណភាព
- រៀបចំសំណើផែនការថវិកាប្រចាំឆ្នាំ សម្រាប់កិច្ចលទ្ធកម្ម ការថែរក្សា ការគ្រប់គ្រង ការដឹកជញ្ជូន និងប្រតិបត្តិការផ្សេងៗពាក់ព័ន្ធនឹងស្បៀងបម្រុងរបស់ក្រុមហ៊ុនហ្គ្រីនត្រេដ នៅក្នុង **ប.ស.ប.ភ.**
- រៀបចំរបាយការណ៍ប្រចាំខែនិងតាមការចាំបាច់ ស្តីពីស្ថានភាពសន្និធិស្បៀងបម្រុងដែលគ្រប់គ្រងដោយផ្ទាល់ និងតាមរយៈកិច្ចសន្យាសហការជាដៃគូជាមួយក្រុមហ៊ុនឯកជននៅក្នុង **ប.ស.ប.ភ.** ដោយបញ្ជាក់ច្បាស់លាស់អំពីបរិមាណនិងគុណភាព ជូនគណៈកម្មាធិការ **ប.ស.ប.ភ.**។

មាត្រា ២៨.-

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវប្រគល់តួនាទីជាអង្គភាពអនុវត្តក្នុង **ប.ស.ប.ភ.** ដល់អគ្គនាយកដ្ឋានកសិកម្ម ដើម្បីបំពេញភារកិច្ចបន្ថែមដូចខាងក្រោម ៖

- ធ្វើការប៉ាន់ប្រមាណអំពីការខូចខាតគ្រប់មុខដំណាំនិងតម្រូវការគ្រាប់ពូជបន្ទាន់
- រៀបចំកិច្ចលទ្ធកម្ម គ្រប់គ្រងការផលិត និងការថែរក្សាជារួមនូវគ្រាប់ពូជស្រូវបម្រុង ពូជបន្លែ និងគ្រាប់ពូជដំណាំរួមផ្សំផ្សេងៗទៀតដែលមានគុណភាព

- ជ្រើសរើសនិងចុះកិច្ចសន្យាសហការជាដៃគូជាមួយក្រុមហ៊ុនឯកជននិងសហគមន៍កសិករ ដែលផលិតគ្រាប់ពូជស្រូវ គ្រាប់ពូជបន្លែ និងគ្រាប់ពូជដំណាំរួមផ្សំផ្សេងៗនៅក្នុង **ប.ស.ប.ក.** ដោយធានាបាននូវបរិមាណ គុណភាព និងការដឹកជញ្ជូនគ្រាប់ពូជទាន់ពេលវេលា ទៅកាន់គោលដៅចែកចាយ
- ធានាដឹកជញ្ជូនគ្រាប់ពូជបម្រុងទាន់ពេលវេលាទៅកាន់គោលដៅចែកចាយ នៅក្នុង **ប.ស.ប.ក.**
- គ្រប់គ្រងបញ្ជីសារពើភណ្ឌនៃសន្និធិគ្រាប់ពូជបម្រុង នៅក្នុងឃ្លាំងស្តុករបស់អគ្គនាយកដ្ឋានកសិកម្ម និងឃ្លាំងស្តុកគ្រាប់ពូជរបស់ក្រុមហ៊ុនឯកជន និងសហគមន៍កសិករ ដែលផលិតគ្រាប់ពូជជាដៃគូ
- គ្រប់គ្រងនិងត្រួតពិនិត្យសន្និធិគ្រាប់ពូជបម្រុង ដើម្បីធានាបរិមាណនិងគុណភាព
- រៀបចំសំណើផែនការថវិកាប្រចាំឆ្នាំ សម្រាប់កិច្ចលទ្ធកម្ម ការផលិត ការថែរក្សា ការគ្រប់គ្រង ការដឹកជញ្ជូន និងប្រតិបត្តិការផ្សេងៗពាក់ព័ន្ធនឹងគ្រាប់ពូជបម្រុងរបស់អគ្គនាយកដ្ឋានកសិកម្ម នៅក្នុង **ប.ស.ប.ក.**
- រៀបចំរបាយការណ៍ប្រចាំខែនិងតាមការចាំបាច់ ស្តីពីស្ថានភាពសន្និធិគ្រាប់ពូជបម្រុងរបស់អគ្គនាយកដ្ឋានកសិកម្មនៅក្នុង **ប.ស.ប.ក.** ដោយបញ្ជាក់យ៉ាងច្បាស់លាស់អំពីបរិមាណ និងគុណភាព ជូនគណៈកម្មាធិការ **ប.ស.ប.ក.**។

មាត្រា ២៩.-

កាកបាទក្រហមកម្ពុជា បណ្តាដៃគូអភិវឌ្ឍ (រួមទាំងទីភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការអន្តរជាតិ) សង្គមស៊ីវិល វិស័យឯកជន និងសប្បុរសជន ត្រូវបានលើកទឹកចិត្តឱ្យចូលរួមគាំទ្រដល់ដំណើរការរបស់ **ប.ស.ប.ក.** ដោយផ្អែកលើកិច្ចសហការនិងសម្របសម្រួលជាមួយគណៈកម្មាធិការ **ប.ស.ប.ក.** តាមរយៈសកម្មភាពជាអាទិភាព ដូចខាងក្រោម៖

- ការចែករំលែកព័ត៌មានស្តីពីតម្រូវការស្បៀងនិងគ្រាប់ពូជ
- ការកំណត់ប្រជាពលរដ្ឋគោលដៅដែលត្រូវទទួលការចែកចាយស្បៀងនិងគ្រាប់ពូជ
- ការផ្តល់កិច្ចគាំទ្រដល់ការចែកចាយស្បៀងនិងគ្រាប់ពូជដល់ប្រជាពលរដ្ឋរងគ្រោះដោយសារគ្រោះមហន្តរាយឬគ្រោះអាសន្ននានា
- ការផ្តល់កិច្ចគាំទ្រផ្នែកបច្ចេកទេសនិងថវិកាសម្រាប់គាំទ្រដល់ការប្រមូលទិន្នន័យ ការប៉ាន់ប្រមាណអំពីតម្រូវការស្បៀងនិងគ្រាប់ពូជបន្ទាន់
- ការចែករំលែកចំណេះដឹងនិងបទពិសោធពាក់ព័ន្ធនឹងប្រតិបត្តិការសង្គ្រោះបន្ទាន់ នៅពេលមានគ្រោះមហន្តរាយឬគ្រោះអាសន្ននានា
- ការផ្តល់កិច្ចគាំទ្រផ្នែកបច្ចេកទេសនិងថវិកាសម្រាប់គាំទ្រដល់សកម្មភាពពាក់ព័ន្ធនឹងសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ

- ការផ្តល់កិច្ចគាំទ្រផ្នែកបច្ចេកទេសនិងថវិកាដល់ស្ថាប័នពាក់ព័ន្ធរបស់ **ម.ស.ម.ក.** សម្រាប់ការពង្រឹងសមត្ថភាពធនធានមនុស្សនិងស្ថាប័ន ព្រមទាំងប្រតិបត្តិការនានា ដែលទាក់ទងទៅនឹងដំណើរការរបស់ **ម.ស.ម.ក.**។

ជំពូកទី៥

ប្រភពធនធាន

មាត្រា ៣០.-

ម.ស.ម.ក. មានថវិកាដោយឡែកដែលជាកញ្ចប់ថវិកាប្រចាំឆ្នាំរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ម.ស.ម.ក. មានប្រភពធនធានមកពីថវិកាជាតិ បណ្តាដៃគូអភិវឌ្ឍ (រួមទាំងទីភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការអន្តរជាតិ) សង្គមស៊ីវិល វិស័យឯកជននិងសប្បុរសជននានា។

មាត្រា ៣១.-

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវរៀបចំថវិកាសម្រាប់ដំណើរការ **ម.ស.ម.ក.** តាមការកំណត់ដូចខាងក្រោម៖

- ធ្វើកិច្ចលទ្ធកម្មសម្រាប់ការទិញអង្ករ ដើម្បីរក្សាទុកជាសន្និធិស្បៀងបម្រុងជាប្រចាំចំនួន ១០ ០០០(ដប់ពាន់)តោន
- ផលិតគ្រាប់ពូជបម្រុងនិងធ្វើកិច្ចលទ្ធកម្មសម្រាប់ការទិញគ្រាប់ពូជបម្រុងជាប្រចាំ ដូចជាគ្រាប់ពូជស្រូវស្រាលមិនប្រកាន់រដូវ ចំនួន២ ០០០(ពីរពាន់)តោន គ្រាប់ពូជបន្លែនិងគ្រាប់ពូជដំណាំរួមផ្សំផ្សេងៗទៀត ចំនួន២៥(ម្ភៃប្រាំ)តោន
- រក្សាទុកមូលនិធិសាច់ប្រាក់បម្រុង ដែលមានតម្លៃសមមូលនឹងអង្ករចំនួន៦ ០០០(ប្រាំមួយពាន់)តោន គ្រាប់ពូជស្រូវស្រាលមិនប្រកាន់រដូវចំនួន ១ ០០០(មួយពាន់)តោន ព្រមទាំងគ្រាប់ពូជបន្លែនិងគ្រាប់ពូជដំណាំរួមផ្សំផ្សេងៗទៀតចំនួន២៥ (ម្ភៃប្រាំ)តោន
- ចំណាយប្រតិបត្តិការផ្សេងៗរបស់ **ម.ស.ម.ក.** ដែលមានជាអាទិ៍ ចំណាយលើការគ្រប់គ្រងនិងការថែរក្សាសន្និធិ ការបំពេញបន្ថែមសន្និធិ ការជួលឃ្លាំង និងប្រតិបត្តិការចែកចាយស្បៀងនិងគ្រាប់ពូជបម្រុង។

មាត្រា ៣២.-

គណនីតម្កល់មូលនិធិប្រាក់បម្រុងត្រូវគ្រប់គ្រងដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

រាល់ចំណូលនិងចំណាយដែលទាក់ទងនឹងដំណើរការរបស់ **ម.ស.ម.ក.** ត្រូវអនុវត្តតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

ជំពូកទី៦

អវសានប្បញ្ញត្តិ

មាត្រា ៣៣.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ៣៤.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ រដ្ឋមន្ត្រី រដ្ឋលេខាធិការក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០១២

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីជម្រាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីស្នើសុំចុះហត្ថលេខា

រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

គាត ឈន់

កន្លែងទទួល៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១៤៧ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការផ្ទេរឥណទានថវិកា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ នស/ ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/ រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/ រកម/ ១២១១/ ០១៩ ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១២
- បានឃើញអនុក្រឹត្យលេខ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីការបន្ថែម និង កែសម្រួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និង រតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឲ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាអគ្គនាយកដ្ឋានពន្ធដារ និង អគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៨៧ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០១១ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១២
- បានឃើញប្រកាសលេខ ១១០៧ សហវ ថ.ប្រក,ចុះថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ២០១១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិ ផ្ទៃក្នុងជំពូក តាមគណនី និងអនុគណនី សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១២
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

89

សម្រេច

មាត្រា១: ត្រូវបានអនុញ្ញាតឲ្យផ្ទេរឥណទានថវិកា ចំនួន ៩៨.០០០.០០០ រៀល (កៅសិបប្រាំបីលានរៀលគត់) ពីជំពូក៦១ (សេវាខាងក្រៅ) មកជំពូក៦០ (ការទិញ) ជូនសាលាឧទ្ធរណ៍ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១២ ។

មាត្រា២: ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូក តាមគណនី និងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់បំពេញតម្រូវការចំណាយទិញសម្ភារះនិងបរិក្ខារបច្ចេកទេសបំពាក់សាលសវនាការរដ្ឋប្បវេណីថ្មី ។

មាត្រា៣: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ លោកប្រធានសាលាឧទ្ធរណ៍ជាអ្នកទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ ២០១២

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

បានយកសេចក្តីជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ១៤៧ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈកម្មការថ្នាក់ជាតិ ពិនិត្យ និងវាយតម្លៃ បញ្ជីឈ្មោះទណ្ឌិតស្នើសុំបន្ធូរបន្ថយទោស និងលើកលែងទោស

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១១/០២១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពន្ធនាគារ
- បានឃើញក្រឹត្យលេខ ២៨ក្រ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ ១៩៨៨ របស់ក្រុមប្រឹក្សារដ្ឋនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៦ ស្តីពីការបង្កើតអគ្គនាយកដ្ឋានពន្ធនាគារ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បន្ទាប់ពីមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

សម្រេច

មាត្រា ១ .-

ត្រូវបានបង្កើតគណៈកម្មការថ្នាក់ជាតិពិនិត្យ និងវាយតម្លៃបញ្ជីឈ្មោះទណ្ឌិតស្នើសុំបន្ធូរបន្ថយទោស និងលើកលែងទោស ដែលមានសមាសភាព ដូចខាងក្រោម :

១- រដ្ឋមន្ត្រីក្រសួងយុត្តិធម៌	ជាប្រធាន
២- រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ទទួលបន្ទុកកិច្ចការពន្ធនាគារ	ជាអនុប្រធានអចិន្ត្រៃយ៍
៣- អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍	ជាអនុប្រធាន
៤- តំណាងក្រុមប្រឹក្សាអ្នកច្បាប់ទីស្តីការគណៈរដ្ឋមន្ត្រី ០១រូប	ជាសមាជិក
៥- ប្រធានក្រុមប្រឹក្សានីតិកម្មក្រសួងមហាផ្ទៃ	ជាសមាជិក
៦- តំណាងក្រសួងយុត្តិធម៌ ០១រូប	ជាសមាជិក
៧- អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធនាគារ	ជាសមាជិក
៨- តំណាងអគ្គស្នងការដ្ឋាននគរបាលជាតិ ០១រូប	ជាសមាជិក
៩- តំណាងអគ្គនាយកដ្ឋានបច្ចេកទេសក្រសួងយុត្តិធម៌ ០១រូប	ជាសមាជិក
១០- ប្រធាននាយកដ្ឋានប្រតិបត្តិ	ជាសមាជិក
១១- ប្រធាននាយកដ្ឋានអប់រំកែប្រែ	ជាសមាជិក
១២- ប្រធានលេខាធិការដ្ឋានគណៈកម្មការថ្នាក់ជាតិ	ជាលេខាធិការ

មាត្រា ២ .-

គណៈកម្មការនេះ មានសិទ្ធិនិងភារកិច្ច ដូចខាងក្រោម ៖

- ធ្វើការផ្សព្វផ្សាយខ្លឹមសារនៃសេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃ អំពីលក្ខណៈសម្បត្តិ និងចំណាត់ថ្នាក់ប្រឡងប្រណាំងខិតខំកសាង កែប្រែគំនិតមារយាទរបស់ទណ្ឌិតម្នាក់ៗក្នុងរយៈពេលរងទោសនៅមណ្ឌលអប់រំកែប្រែ និងនៅពន្ធនាគាររាជធានី ខេត្ត
- ធ្វើការណែនាំដល់គណៈកម្មការរាជធានី ខេត្តនិងគណៈកម្មការក្រសួងមហាផ្ទៃ អំពីរបៀបគិតគូររយៈពេលរងទោសក្នុងមណ្ឌលអប់រំកែប្រែ និងពន្ធនាគាររាជធានី ខេត្ត និងរបៀបវាយតម្លៃកម្រិតនៃការកែប្រែនិងលក្ខណៈសម្បត្តិរបស់ទណ្ឌិតដែលត្រូវស្នើសុំបន្ធូរបន្ថយទោស និងលើកលែងទោស
- ធ្វើការជាស់តឿនក្រើនរំលឹកដល់គណៈកម្មការរាជធានី ខេត្ត និងគណៈកម្មការក្រសួងមហាផ្ទៃឱ្យរួសរាន់បញ្ជូនបញ្ជីឈ្មោះទណ្ឌិតដែលត្រូវស្នើសុំបន្ធូរបន្ថយទោសនិងលើកលែងទោសមកគណៈកម្មការថ្នាក់ជាតិឱ្យបានទាន់ពេលវេលាតាមការកំណត់នៃច្បាប់
- ពិនិត្យរបាយការណ៍វាយតម្លៃអំពីកម្រិតកែប្រែរបស់ទណ្ឌិតម្នាក់ៗក្នុងរយៈពេលរងទោសនៅមណ្ឌលអប់រំកែប្រែ និងនៅពន្ធនាគាររាជធានី ខេត្ត

- ធ្វើការផ្ទៀងផ្ទាត់រយៈពេលរងទោសក្នុងពន្ធនាគាររបស់ទណ្ឌិតម្នាក់ៗ តាមបញ្ជីឈ្មោះទណ្ឌិតស្នើសុំបន្ធូរបន្ថយទោសនិងលើកលែងទោសជាមួយរយៈពេលរងទោសដែលកំណត់នៅក្នុងសាលក្រម ឬសាលដីការបស់តុលាការ
- ពិនិត្យ និងសម្រេចបញ្ជីឈ្មោះទណ្ឌិត ដែលត្រូវស្នើសុំបន្ធូរបន្ថយទោស និងលើកលែងទោសរបស់គណៈកម្មការរាជធានី ខេត្ត និងគណៈកម្មការក្រសួងមហាផ្ទៃ
- រៀបចំបែបបទជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច ដើម្បីធ្វើសំណើថ្វាយព្រះមហាក្សត្រសុំបន្ធូរបន្ថយទោស និងលើកលែងទោសឱ្យទណ្ឌិត
- អញ្ជើញប្រធានគណៈកម្មការរាជធានី ខេត្ត ឬប្រធានគណៈកម្មការក្រសួងមហាផ្ទៃ ឬបុគ្គលពាក់ព័ន្ធផ្សេងទៀត ឱ្យមកបំភ្លឺប្រសិនបើយល់ឃើញថាចាំបាច់។

មាត្រា ៣ .-

សមាជិកគណៈកម្មការថ្នាក់ជាតិពិនិត្យ និងវាយតម្លៃបញ្ជីឈ្មោះទណ្ឌិតស្នើសុំបន្ធូរបន្ថយទោស និងលើកលែងទោសត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីប្រធានអវត្តមាន អនុប្រធានអចិន្ត្រៃយ៍មានសិទ្ធិកោះអញ្ជើញ និងដឹកនាំអង្គប្រជុំជំនួសតាមការប្រគល់សិទ្ធិរបស់ប្រធាន។

មាត្រា ៤ .-

គណៈកម្មការថ្នាក់ជាតិពិនិត្យ និងវាយតម្លៃបញ្ជីឈ្មោះទណ្ឌិតស្នើសុំបន្ធូរបន្ថយទោស និងលើកលែងទោសមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងយុត្តិធម៌។

មាត្រា ៥ .-

គណៈកម្មការថ្នាក់ជាតិពិនិត្យ និងវាយតម្លៃបញ្ជីឈ្មោះទណ្ឌិតស្នើសុំបន្ធូរបន្ថយទោស និងលើកលែងទោស ត្រូវមានលេខាធិការដ្ឋានមួយដែលមានទីតាំងនៅក្នុងទីស្តីការរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

មាត្រា ៦ .-

លេខាធិការដ្ឋានគណៈកម្មការថ្នាក់ជាតិត្រូវដឹកនាំដោយប្រធានមួយរូបនិងមានអនុប្រធានមួយចំនួនជាជំនួយការ។ មន្ត្រីបម្រើការងារក្នុងលេខាធិការដ្ឋាននេះ ត្រូវបានជ្រើសរើសចេញពីមន្ត្រីក្របខ័ណ្ឌរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌។

មាត្រា ៧ .-

សមាសភាព និងភារកិច្ចរបស់លេខាធិការដ្ឋាន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

មាត្រា ៨ .-

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ៩ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលមានការពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ [illegible] ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
នៃព្រះរាជាណាចក្រកម្ពុជា សូមចុះហត្ថលេខា។

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ស ខេង

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

អង្គ វង្សវឌ្ឍានា

***កន្លែងទទួល*:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៩
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៤៥.អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការកាត់ចេញពីផែនទីតម្រូវព្រៃឈើអចិន្ត្រៃយ៍ឆ្នាំ២០០២ និង ពីគម្រោងសម្បទានដីសេដ្ឋកិច្ចនិងព្រៃសម្បទាន នៅខេត្តក្រចេះ នូវផ្ទៃដីសរុបចំនួន ១៩០០ ហិកតា និងធ្វើអនុបយោគមកជាដីឯកជនរបស់រដ្ឋ ដើម្បីធ្វើប្រទានកម្មជូនប្រជាពលរដ្ឋដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នស ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ០២ សរ ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្តីពីការប្រឡងប្រណាំងកែលំអសោភ័ណភាពខេត្តទូទាំងប្រទេស

- បានឃើញសារាចរលេខ ០៥ សរ ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០០ របស់រាជរដ្ឋាភិបាលស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- តាមសំណើលេខ៥៧៩ល.ក្រច ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១២ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តក្រចេះ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា ១.-

ត្រូវបានកាត់ចេញពីគម្របព្រៃឈើ និងធ្វើអនុបយោគជាដីឯករបស់រដ្ឋនូវ៖

– ចំណែកផ្ទៃដីទំហំ ៩៤៣ (ប្រាំបួនរយសែសិបបី) ហិកតា ដែលស្ថិតក្នុងគម្រោងដីព្រៃសម្បទានរបស់ក្រុមហ៊ុន សាមលីញ តាមកិច្ចព្រមព្រៀងចុះថ្ងៃទី១១ ខែសីហា ឆ្នាំ ១៩៩៤ របស់ទីស្តីការ គណៈរដ្ឋមន្ត្រី ដែលមានទីតាំងស្ថិតនៅក្នុងឃុំស្រែចារ និងឃុំ២ធ្នូ ស្រុកស្នួល ខេត្តក្រចេះ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងដែលមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

– ចំណែកផ្ទៃដីទំហំ ៤៣ (សែសិបបី) ហិកតា ដែលស្ថិតក្នុងគម្រោងដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ហៃ យ៉ុង តាមលិខិតលេខ ១៧១០ ស.ជ.ណ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៧ របស់ទីស្តីការ គណៈរដ្ឋមន្ត្រីសម្រាប់វិនិយោគដាំដំណាំកសិ-ឧស្សាហកម្ម ដែលមាន ទីតាំងស្ថិតនៅក្នុងឃុំ២ធ្នូ ស្រុកស្នួល ខេត្តក្រចេះ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងដែលមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

– ចំណែកផ្ទៃដីទំហំ ៩១៤ (ប្រាំបួនរយដប់បួន) ហិកតា ដែលស្ថិតក្នុងគម្រោងដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ស៊ីអាយវី តាមលិខិតលេខ ១៧១០ ស.ជ.ណ-ជស ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៧ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីករណីសំណើសុំដីសម្បទានសេដ្ឋកិច្ច ដែលមានទីតាំងស្ថិតនៅក្នុងឃុំស្រែចារ និងឃុំ២ធ្នូ ស្រុកស្នួល ខេត្តក្រចេះ និងដែលមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

មាត្រា ២.-

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តក្រចេះ ធ្វើការគ្រប់គ្រងនិងប្រទានកម្មជូនប្រជាពលរដ្ឋចំនួន ៥៦០ (ប្រាំរយហុកសិប) គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង ក្នុងនោះមាន៖

- ចំនួន ៣១១ គ្រួសារ ស្ថិតក្នុងចំណែកដីត្រូវកាត់ចេញពីក្រុមហ៊ុន សាមលីញ
- ចំនួន ១៦ គ្រួសារ ស្ថិតក្នុងចំណែកដីត្រូវកាត់ចេញពីក្រុមហ៊ុន ហៃ យ៉ុង
- ចំនួន ២៣៣ គ្រួសារ ស្ថិតក្នុងចំណែកដីត្រូវកាត់ចេញពីក្រុមហ៊ុន ស៊ី អាយ វី

មាត្រា ៣ .-

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តក្រចេះ ត្រូវគិតបញ្ចូលនិងកាត់ចេញនូវចំណែកដីមួយចំនួនដែលនឹងត្រូវរក្សាទុកសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត សាធារណៈ និងសង្គមក្នុងមូលដ្ឋានផ្ទាល់។

មាត្រា ៤ ._

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៥._

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងពាក់ពន្ធ័ និងអភិបាលនៃគណៈអភិបាលខេត្តក្រចេះ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ២០១២

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

ចម្លងជូន៖
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារកាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៥០ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការទទួលស្គាល់វិទ្យាស្ថាន អេសធី ខ្លេម៉ិនស៍

* * * * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញអនុក្រឹត្យលេខ ៨៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខណវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

ស ម្រេ ច

មាត្រា ១.-

ត្រូវបានទទួលស្គាល់ការបង្កើតគ្រឹះស្ថានឧត្តមសិក្សាឯកជនមួយ ដែលមានឈ្មោះថា វិទ្យាស្ថាន អេសធី ខ្លេម៉ិនស៍ (ST CLEMENTS INSTITUTE) សរសេរកាត់ជាភាសាខ្មែរ "វ.អ.ខ" និងសរសេរកាត់ជាភាសាអង់គ្លេស "S.C.I" ។

មាត្រា ២.-

វិទ្យាស្ថាន អេសធី ខ្មែរមិនស៍ មានទីតាំងស្ថិតនៅអគារលេខ១០២ ផ្លូវ៥៩៨ សង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ និងស្ថិតនៅក្រោមឱវាទរបស់ក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ៣.-

វិទ្យាស្ថាន អេសធី ខ្មែរមិនស៍ ធ្វើការបណ្តុះបណ្តាលកម្រិតបរិញ្ញាបត្រ និងបរិញ្ញាបត្ររង លើដេប៉ាតឺម៉ង់ ចំនួន២ ដែលមានឯកទេសដូចខាងក្រោម ៖

១- ដេប៉ាតឺម៉ង់វិទ្យាសាស្ត្រសង្គម និងសេដ្ឋកិច្ច ៖
- ឯកទេសបដិសណ្ឋារកិច្ច និងទេសចរណ៍
- ឯកទេសគ្រប់គ្រងហិរញ្ញវត្ថុ និងធនាគារ
- ឯកទេសគ្រប់គ្រងពាណិជ្ជកម្ម

២- ដេប៉ាតឺម៉ង់បច្ចេកវិទ្យាព័ត៌មាន ៖
- ឯកទេសបច្ចេកវិទ្យាព័ត៌មាន

វិទ្យាស្ថាន អេសធី ខ្មែរមិនស៍ ត្រូវរៀបចំកម្មវិធីសិក្សាលម្អិត តាមកម្រិត និងមុខជំនាញ ដើម្បីសុំការឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា មុននឹងចាប់ផ្តើមដំណើរការបណ្តុះបណ្តាល ។ ទៅអនាគត វិទ្យាស្ថាននេះអាចបើកសាខាដេប៉ាតឺម៉ង់ថ្មី មុខជំនាញថ្មី កម្រិតឬថ្នាក់ថ្មី ប្រភេទបណ្តុះបណ្តាលថ្មី ប្តូរឈ្មោះថ្មីឬទីតាំងថ្មី ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ៤.-

វិទ្យាស្ថាន អេសធី ខ្មែរមិនស៍ ត្រូវមានក្រុមប្រឹក្សាភិបាលមួយ ដើម្បីពិនិត្យ និងសម្រេចលើគោលនយោបាយ ផែនការអភិវឌ្ឍកម្មវិធីសិក្សា និងការងារបច្ចេកទេសពាក់ព័ន្ធដទៃទៀត។ ការរៀបចំក្រុមប្រឹក្សាភិបាល ត្រូវមានការឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ៥.-

នាយកវិទ្យាស្ថាន អេសធី ខ្មែរមិនស៍ មានភារកិច្ច ៖
- ទទួលខុសត្រូវចំពោះមុខច្បាប់ ក្នុងការគ្រប់គ្រងវិទ្យាស្ថាន អេសធី ខ្មែរមិនស៍ និងធានាឱ្យមានសុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គម
- ទទួលខុសត្រូវក្នុងការជ្រើសរើសនិស្សិតឲ្យចូលរៀន និងទទួលនិស្សិតឲ្យសិក្សាបន្ត តាមកម្មវិធីសិក្សារបស់វិទ្យាស្ថាន
- គោរព និងអនុវត្តតាមការណែនាំ និងបទដ្ឋានរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលកំណត់លើសកម្មភាពនៃការធានាគុណភាពអប់រំ
- រៀបចំតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធគ្រប់គ្រងវិទ្យាស្ថាន និងវិធានផ្ទៃក្នុង សម្រាប់ការគ្រប់គ្រងការសិក្សាឲ្យបានច្បាស់លាស់
- ធ្វើរបាយការណ៍ប្រចាំឆ្នាំអំពីការងារបណ្តុះបណ្តាលមកក្រសួងអប់រំ យុវជន និងកីឡា តាមការកំណត់ ។/.

មាត្រា ៦.-

និស្សិតវិទ្យាស្ថាន អេសធី ខ្លេម៉ិនស៍ ដែលបានរៀនចប់កម្មវិធីសិក្សា និងទទួលបានជោគជ័យក្នុងការបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាបត្រតាមកម្រិត និងមុខជំនាញដែលបានសិក្សា ។ សញ្ញាបត្រនេះ ផ្តល់ឱ្យដោយវិទ្យាស្ថាន អេសធី ខ្លេម៉ិនស៍ ហើយត្រូវបានទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណីវិទ្យាស្ថាន អេសធី ខ្លេម៉ិនស៍ បំពេញ និងអនុវត្តបានតាមគោលការណ៍ និងបទដ្ឋានរបស់ក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ៧.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងក្រុមប្រឹក្សាភិបាល រួមនាយកនៃវិទ្យាស្ថាន អេសធី ខ្លេម៉ិនស៍ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ៕

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល ៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- សាលារាជធានីភ្នំពេញ
- ដូចមាត្រា ៧
- រាជកិច្ច
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ១១៧១ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការដំឡើងថ្នាក់មន្ត្រីរាជការ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥១ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពី លក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៤០ ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពី លក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម
-បានឃើញអនុក្រឹត្យលេខ ៨៤ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
-បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-បានឃើញអនុក្រឹត្យលេខ ៩១ អនក្រ.បក ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
-បានឃើញអនុក្រឹត្យលេខ ០២ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
-តាមសំណើរបស់រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

សម្រេច

មាត្រា១.. ត្រូវបានដំឡើងថ្នាក់ប្រចាំឆ្នាំជូនមន្ត្រីរាជការចំនួន ៥៥ រូប ក្នុងឋានន្តរស័ក្តិរមន្ត្រី នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ចាប់ពីថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០១២ របស់ក្រសួង ស្ថប័ន ដូចមានរាយនាមខាងក្រោម ៖

ក្រសួងអប់រំ យុវជន និងកីឡា				
ល.រ	នាមនិង គោត្តនាម	ភេទ	ឋានន្តរស័ក្តិ និង ថ្នាក់ចាស់	ឋានន្តរស័ក្តិ និង ថ្នាក់ត្រូវដំឡើង
១	**ខ៉ាន់ សុមេធ**	ប	ពីរមន្ត្រី ថ្នាក់លេខ ២	ទៅរមន្ត្រី ថ្នាក់លេខ ១
២	**លី សទ្ធិ**	ប	ពីរមន្ត្រី ថ្នាក់លេខ ៣	ទៅរមន្ត្រី ថ្នាក់លេខ ២
៣	**សេង ម៉ុនធឿន**	ប	ពីរមន្ត្រី ថ្នាក់លេខ ៥	ទៅរមន្ត្រី ថ្នាក់លេខ ៤
៤	**ឱម សិទ្ធី**	ប	ពីរមន្ត្រី ថ្នាក់លេខ ៦	ទៅរមន្ត្រី ថ្នាក់លេខ ៥
៥	**ច័ន្ទ រ័ត្ន**	ប	ពីរមន្ត្រី ថ្នាក់លេខ ៨	ទៅរមន្ត្រី ថ្នាក់លេខ ៧
៦	**អូន ច័ន្ទស៊ីយ៉ាឌុឡេន៍**	ប	ពីរមន្ត្រី ថ្នាក់លេខ ៨	ទៅរមន្ត្រី ថ្នាក់លេខ ៧
ក្រសួងពាណិជ្ជកម្ម				
ល.រ	នាមនិង គោត្តនាម	ភេទ	ឋានន្តរស័ក្តិ និង ថ្នាក់ចាស់	ឋានន្តរស័ក្តិ និង ថ្នាក់ត្រូវដំឡើង
១	**ស៊ុត តារា**	ប	ពីរមន្ត្រី ថ្នាក់លេខ ៣	ទៅរមន្ត្រី ថ្នាក់លេខ ២
២	**រាម តាទ**	ប	ពីរមន្ត្រី ថ្នាក់លេខ ៥	ទៅរមន្ត្រី ថ្នាក់លេខ ៤
៣	**អាំង សុជាតិ**	ប	ពីរមន្ត្រី ថ្នាក់លេខ ៥	ទៅរមន្ត្រី ថ្នាក់លេខ ៤
៤	**អ៊ុន ម៉ុនថា**	ប	ពីរមន្ត្រី ថ្នាក់លេខ ៥	ទៅរមន្ត្រី ថ្នាក់លេខ ៤

៥	**ទង ច័ន្ទតារា**	ប	ពីវរមន្ត្រី ថ្នាក់លេខ ៥	ទៅវរមន្ត្រី ថ្នាក់លេខ ៤
៦	**ឆន់ ធីរៈ**	ប	ពីវរមន្ត្រី ថ្នាក់លេខ ៦	ទៅវរមន្ត្រី ថ្នាក់លេខ ៥
៧	**ឈីម ខាន់**	ប	ពីវរមន្ត្រី ថ្នាក់លេខ ៧	ទៅវរមន្ត្រី ថ្នាក់លេខ ៦
៨	**មុំ ច័ន្ទតារា**	ប	ពីវរមន្ត្រី ថ្នាក់លេខ ៧	ទៅវរមន្ត្រី ថ្នាក់លេខ ៦
៩	**អ៊ុក ធី**	ប	ពីវរមន្ត្រី ថ្នាក់លេខ ៨	ទៅវរមន្ត្រី ថ្នាក់លេខ ៧
១០	**អ៊ុច គីមយ៉ុន**	ប	ពីវរមន្ត្រី ថ្នាក់លេខ ៨	ទៅវរមន្ត្រី ថ្នាក់លេខ ៧
១១	**ស៊ាង ថៃ**	ប	ពីវរមន្ត្រី ថ្នាក់លេខ ៨	ទៅវរមន្ត្រី ថ្នាក់លេខ ៧
១២	**ម៉ក់ ឧសភា**	ប	ពីវរមន្ត្រី ថ្នាក់លេខ ៩	ទៅវរមន្ត្រី ថ្នាក់លេខ ៨
១៣	**ស៊ុំ ណារុន**	ប	ពីវរមន្ត្រី ថ្នាក់លេខ ១០	ទៅវរមន្ត្រី ថ្នាក់លេខ ៩
១៤	**ឌឹម ថេង**	ប	ពីវរមន្ត្រី ថ្នាក់លេខ ១០	ទៅវរមន្ត្រី ថ្នាក់លេខ ៩
១៥	**សារឿន កេសរា**	ប	ពីវរមន្ត្រី ថ្នាក់លេខ ១០	ទៅវរមន្ត្រី ថ្នាក់លេខ ៩
១៦	**គង់ ពុទ្ធារ៉ា**	ប	ពីវរមន្ត្រី ថ្នាក់លេខ ១០	ទៅវរមន្ត្រី ថ្នាក់លេខ ៩
១៧	**ចម បុរិទ្ធ**	ប	ពីវរមន្ត្រី ថ្នាក់លេខ ១០	ទៅវរមន្ត្រី ថ្នាក់លេខ ៩
ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់				
ល.រ	នាមនិង គោត្តនាម	ភេទ	ឋានន្តរស័ក្តិ និង ថ្នាក់ចាស់	ឋានន្តរស័ក្តិ និង ថ្នាក់ត្រូវដំឡើង
១	**កែវ កុសល**	ប	ពីវរមន្ត្រី ថ្នាក់លេខ ៣	ទៅវរមន្ត្រី ថ្នាក់លេខ ២
២	**សរ សាមេធា**	ប	ពីវរមន្ត្រី ថ្នាក់លេខ ៤	ទៅវរមន្ត្រី ថ្នាក់លេខ ៣
៣	**ញ៉ូន ស៊ី**	ប	ពីវរមន្ត្រី ថ្នាក់លេខ ៤	ទៅវរមន្ត្រី ថ្នាក់លេខ ៣
៤	**ជាម សុផល**	ប	ពីវរមន្ត្រី ថ្នាក់លេខ ៥	ទៅវរមន្ត្រី ថ្នាក់លេខ ៤
៥	**ជី ស៊ីថា**	ប	ពីវរមន្ត្រី ថ្នាក់លេខ ៦	ទៅវរមន្ត្រី ថ្នាក់លេខ ៥
៦	**អ៊ិត សុត្ថា**	ប	ពីវរមន្ត្រី ថ្នាក់លេខ ៦	ទៅវរមន្ត្រី ថ្នាក់លេខ ៥
៧	**ហាង ប៊ុណ្ណាក់**	ប	ពីវរមន្ត្រី ថ្នាក់លេខ ៦	ទៅវរមន្ត្រី ថ្នាក់លេខ ៥
៨	**សួស សុផល**	ស	ពីវរមន្ត្រី ថ្នាក់លេខ ៦	ទៅវរមន្ត្រី ថ្នាក់លេខ ៥
៩	**ជា ផលរី**	ប	ពីវរមន្ត្រី ថ្នាក់លេខ ៨	ទៅវរមន្ត្រី ថ្នាក់លេខ ៧
១០	**សរ សុវណ្ណ**	ប	ពីវរមន្ត្រី ថ្នាក់លេខ ៨	ទៅវរមន្ត្រី ថ្នាក់លេខ ៧
១១	**ឡោ ជាវុធ**	ប	ពីវរមន្ត្រី ថ្នាក់លេខ ៨	ទៅវរមន្ត្រី ថ្នាក់លេខ ៧
១២	**ប្រាក់ អង្គារ៉ា**	ប	ពីវរមន្ត្រី ថ្នាក់លេខ ៨	ទៅវរមន្ត្រី ថ្នាក់លេខ ៧
១៣	**តឿង សុភ័ណ្ណ**	ប	ពីវរមន្ត្រី ថ្នាក់លេខ ៩	ទៅវរមន្ត្រី ថ្នាក់លេខ ៨
១៤	**ផូរ វុឌ្ឍី**	ប	ពីវរមន្ត្រី ថ្នាក់លេខ ៩	ទៅវរមន្ត្រី ថ្នាក់លេខ ៨
១៥	**ឡៅ ទិព្វសីហា**	ប	ពីវរមន្ត្រី ថ្នាក់លេខ ៩	ទៅវរមន្ត្រី ថ្នាក់លេខ ៨
១៦	**សួន សុផា**	ប	ពីវរមន្ត្រី ថ្នាក់លេខ ៩	ទៅវរមន្ត្រី ថ្នាក់លេខ ៨
១៧	**សោ វណ្ណា**	ប	ពីវរមន្ត្រី ថ្នាក់លេខ ៩	ទៅវរមន្ត្រី ថ្នាក់លេខ ៨
១៨	**ប៉ែន សុផល**	ប	ពីវរមន្ត្រី ថ្នាក់លេខ ៩	ទៅវរមន្ត្រី ថ្នាក់លេខ ៨
១៩	**សាយ និដ្ឋា**	ប	ពីវរមន្ត្រី ថ្នាក់លេខ ១០	ទៅវរមន្ត្រី ថ្នាក់លេខ ៩

២០	**បេងហុង សុជាតិខេមរ៉ូ**	ប	ពីវរមន្ត្រី ថ្នាក់លេខ ១០	ទៅវរមន្ត្រី ថ្នាក់លេខ ៩
២១	**សារ៉េត បុរាមី**	ប	ពីវរមន្ត្រី ថ្នាក់លេខ ១០	ទៅវរមន្ត្រី ថ្នាក់លេខ ៩
២២	**ទៅ សុខា**	ប	ពីវរមន្ត្រី ថ្នាក់លេខ ១០	ទៅវរមន្ត្រី ថ្នាក់លេខ ៩
រដ្ឋលេខាធិការដ្ឋាន អាកាសចរស៊ីវិល				
ល.រ	នាម និង គោត្តនាម	ភេទ	ឋានន្តរស័ក្តិ និង ថ្នាក់ចាស់	ឋានន្តរស័ក្តិ និង ថ្នាក់ត្រូវដំឡើង
១	**រំចេក សុខ៉ារី**	ប	ពីវរមន្ត្រី ថ្នាក់លេខ ២	ទៅវរមន្ត្រី ថ្នាក់លេខ ១
២	**សេង ម៉ានី**	ប	ពីវរមន្ត្រី ថ្នាក់លេខ ២	ទៅវរមន្ត្រី ថ្នាក់លេខ ១
៣	**ឃុន ហ៊ី**	ប	ពីវរមន្ត្រី ថ្នាក់លេខ ២	ទៅវរមន្ត្រី ថ្នាក់លេខ ១
៤	**ទេព សុន្ទរី**	ស	ពីវរមន្ត្រី ថ្នាក់លេខ ៣	ទៅវរមន្ត្រី ថ្នាក់លេខ ២
៥	**មុំ សារ៉េត**	ប	ពីវរមន្ត្រី ថ្នាក់លេខ ៣	ទៅវរមន្ត្រី ថ្នាក់លេខ ២
៦	**កែវ ស៊ីវន**	ប	ពីវរមន្ត្រី ថ្នាក់លេខ ៤	ទៅវរមន្ត្រី ថ្នាក់លេខ ៣
៧	**ស៊ីន ចាន់សិរីវុត្ថា**	ប	ពីវរមន្ត្រី ថ្នាក់លេខ ៧	ទៅវរមន្ត្រី ថ្នាក់លេខ ៦
៨	**ប៉ាន់ ចាន់ឡារ័ត្ន**	ប	ពីវរមន្ត្រី ថ្នាក់លេខ ៧	ទៅវរមន្ត្រី ថ្នាក់លេខ ៦
៩	**ប៊ុន រដ្ឋា**	ប	ពីវរមន្ត្រី ថ្នាក់លេខ ៨	ទៅវរមន្ត្រី ថ្នាក់លេខ ៧
១០	**ខាន់ វណ្ណា**	ប	ពីវរមន្ត្រី ថ្នាក់លេខ ១០	ទៅវរមន្ត្រី ថ្នាក់លេខ ៩

មាត្រា២.. ត្រូវបានដំឡើងថ្នាក់ប្រចាំឆ្នាំជូនមន្ត្រីរាជការចំនួន ០២ រូប ក្នុងឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ នៃក្របខណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ចាប់ពីថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០១២ របស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ដូចមានរាយនាមខាងក្រោម៖

ល.រ	នាម និង គោត្តនាម	ភេទ	ឋានន្តរស័ក្តិ និង ថ្នាក់ចាស់	ឋានន្តរស័ក្តិ និង ថ្នាក់ត្រូវដំឡើង
១	**សុខ ពុធធឿន**	ប	ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៦	ទៅមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៥
២	**ពាង សារី**	ប	ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៥	ទៅមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៤

មាត្រា៣.. ត្រូវបានដំឡើងថ្នាក់តាមកម្រិតសញ្ញាបត្រជូនមន្ត្រីរាជការចំនួន ០៨ រូប ក្នុងឋានន្តរស័ក្តិវរមន្ត្រី នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល និងឋានន្តរស័ក្តិគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ នៃក្របខណ្ឌគ្រូបង្រៀនកម្រិតឧត្តម របស់ក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ៖

ល.រ	នាមនិង គោត្តនាម	ភេទ	ឋានន្តរស័ក្តិ និង ថ្នាក់ចាស់	ឋានន្តរស័ក្តិ និង ថ្នាក់ត្រូវដំឡើង
១	**ខាន់ ច័ន្ទផេន**	ប	ពីវរមន្ត្រី ថ្នាក់លេខ ៧	ទៅវរមន្ត្រី ថ្នាក់លេខ ៦
២	**លាង សេងហាក់**	ប	ពីវរមន្ត្រី ថ្នាក់លេខ ៧	ទៅវរមន្ត្រី ថ្នាក់លេខ ៦
៣	**ម៉ក់ ខយ**	ប	ពីវរមន្ត្រី ថ្នាក់លេខ ១០	ទៅវរមន្ត្រី ថ្នាក់លេខ ៩
៤	**មាស សុខុម**	ប	ពីគ្រូបង្រៀនកម្រិតឧត្តម ដើមខ្សែ ថ្នាក់លេខ ៧	ទៅគ្រូបង្រៀនកម្រិតឧត្តម ដើមខ្សែ ថ្នាក់លេខ ៦
៥	**លឹម សុចាន់**	ប	ពីគ្រូបង្រៀនកម្រិតឧត្តម ដើមខ្សែ ថ្នាក់លេខ ៩	ទៅគ្រូបង្រៀនកម្រិតឧត្តម ដើមខ្សែ ថ្នាក់លេខ ៨

៦	**នៅ រ៉ា**	ប	ពីគ្រូបង្រៀនកម្រិតឧត្តម ដើមខ្សែ ថ្នាក់លេខ ១០	ទៅគ្រូបង្រៀនកម្រិតឧត្តម ដើមខ្សែ ថ្នាក់លេខ ៩
៧	**ហាក់ ធឿន**	ប	ពីគ្រូបង្រៀនកម្រិតឧត្តម ដើមខ្សែ ថ្នាក់លេខ ១០	ទៅគ្រូបង្រៀនកម្រិតឧត្តម ដើមខ្សែ ថ្នាក់លេខ ៩
៨	**សុខ សុភោម៉ា**	ប	ពីគ្រូបង្រៀនកម្រិតឧត្តម ដើមខ្សែ ថ្នាក់លេខ ១០	ទៅគ្រូបង្រៀនកម្រិតឧត្តម ដើមខ្សែ ថ្នាក់លេខ ៩

មាត្រា៤.- មន្ត្រីរាជការដែលត្រូវបានដំឡើងថ្នាក់ដូចមានឈ្មោះក្នុងមាត្រា ៣ ខាងលើ ត្រូវរក្សាទុកអតីតភាពសម្រាប់ឡើងថ្នាក់តាមវេនជ្រើសរើស និងវេនអតីតភាពជដែល។

មាត្រា៥.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ មាត្រា២ និងមាត្រា៣ ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ [illegible] ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១១៧២ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការដំឡើងឋានន្តរស័ក្តិ និងថ្នាក់មន្ត្រីរាជការ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសុខាភិបាល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៦៣ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៤០ ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខណ្ឌគ្រូបង្រៀនកម្រិតឧត្តម
-បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
-បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-បានឃើញអនុក្រឹត្យលេខ ៥៨ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធនធានទឹក និងឧតុនិយម
-បានឃើញអនុក្រឹត្យលេខ ៨៤ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
-បានឃើញអនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
-បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-តាមសំណើរបស់រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

សម្រេច

មាត្រា១.- ត្រូវបានដំឡើងឋានន្តរស័ក្តិជូនមន្ត្រីរាជការចំនួន ០៧ រូប ពីឋានន្តរស័ក្តិអនុមន្ត្រី ទៅវរមន្ត្រី នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល របស់ក្រសួង ស្ថាប័ន ដូចមានរាយនាមខាងក្រោម ៖

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ				
ល.រ	នាម និងគោត្តនាម	ភេទ	ឋានន្តរស័ក្តិ និងថ្នាក់ចាស់	ឋានន្តរស័ក្តិ និងថ្នាក់ត្រូវដំឡើង
១	**គីម កែវមុនីវត្ថ**	ប	ពីអនុមន្ត្រី ថ្នាក់លេខ ១១	ទៅវរមន្ត្រី ថ្នាក់លេខ ១០
ក្រសួងធនធានទឹក និងឧតុនិយម				
ល.រ	នាម និងគោត្តនាម	ភេទ	ឋានន្តរស័ក្តិ និងថ្នាក់ចាស់	ឋានន្តរស័ក្តិ និងថ្នាក់ត្រូវដំឡើង
១	**សុខ មុនីរតនា**	ប	ពីអនុមន្ត្រី ថ្នាក់លេខ ៥	ទៅវរមន្ត្រី ថ្នាក់លេខ ៧
២	**ឡឹង សុធាច័ន្ទនី**	ប	ពីអនុមន្ត្រី ថ្នាក់លេខ ៦	ទៅវរមន្ត្រី ថ្នាក់លេខ ៧
៣	**ឡុង សាំងទុន**	ប	ពីអនុមន្ត្រី ថ្នាក់លេខ ៧	ទៅវរមន្ត្រី ថ្នាក់លេខ ៨
៤	**ចាន់ ស៊ីណាត**	ប	ពីអនុមន្ត្រី ថ្នាក់លេខ ៩	ទៅវរមន្ត្រី ថ្នាក់លេខ ១០
ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ				
ល.រ	នាម និងគោត្តនាម	ភេទ	ឋានន្តរស័ក្តិ និងថ្នាក់ចាស់	ឋានន្តរស័ក្តិ និងថ្នាក់ត្រូវដំឡើង
១	**ឡាយ សំអូន**	ប	ពីអនុមន្ត្រី ថ្នាក់លេខ ១១	ទៅវរមន្ត្រី ថ្នាក់លេខ ១០

ក្រសួងអប់រំ យុវជន និងកីឡា				
ល.រ	នាម និងគោត្តនាម	ភេទ	ឋានន្តរស័ក្តិ និងថ្នាក់ចាស់	ឋានន្តរស័ក្តិ និងថ្នាក់ត្រូវដំឡើង
១	**សារ ណារ៉ាក់**	ប	ពីអនុមន្ត្រី ថ្នាក់លេខ ៨	ទៅវរមន្ត្រី ថ្នាក់លេខ ៩

មាត្រា២.- ត្រូវបានដំឡើងឋានន្តរស័ក្តិជូនមន្ត្រីរាជការចំនួន ០២ រូប ពីឋានន្តរស័ក្តិមន្ត្រីសុខាភិបាលជាន់ខ្ពស់ ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ នៃក្របខណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ របស់ក្រសួងសុខាភិបាល ដូចមានរាយនាមខាងក្រោម ៖

ក្រសួងសុខាភិបាល				
ល.រ	នាម និងគោត្តនាម	ភេទ	ឋានន្តរស័ក្តិ និងថ្នាក់ចាស់	ឋានន្តរស័ក្តិ និងថ្នាក់ត្រូវដំឡើង
១	**អ៊ុង សារ៉ាន់**	ប	ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១១	ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ១០
២	**លី ធីរៈ**	ប	ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១១	ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ១០

មាត្រា៣.- ត្រូវបានដំឡើងឋានន្តរស័ក្តិជូនមន្ត្រីរាជការចំនួន ០៥ រូប ពីឋានន្តរស័ក្តិគ្រូបង្រៀនកម្រិតឧត្តម ទៅគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ នៃក្របខណ្ឌគ្រូបង្រៀនកម្រិតឧត្តម របស់ក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ៖

ក្រសួងអប់រំ យុវជន និងកីឡា				
ល.រ	នាម និងគោត្តនាម	ភេទ	ឋានន្តរស័ក្តិ និងថ្នាក់ចាស់	ឋានន្តរស័ក្តិ និងថ្នាក់ត្រូវដំឡើង
១	**ប៉ាល់ វ៉ែងស**	ប	ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៨	ទៅគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៩
២	**សួស យុត្ថារី**	ប	ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៩	ទៅគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១០
៣	**រស់ វណ្ណជ័យ**	ប	ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១០	ទៅគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១០
៤	**នួន ទីវ៉ា**	ប	ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១១	ទៅគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១០
៥	**យាន សំបូរ**	ប	ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១០	ទៅគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១០

មាត្រា៤.- ត្រូវបានដំឡើងថ្នាក់តាមកម្រិតសញ្ញាបត្រជូនមន្ត្រីរាជការចំនួន ០៣ រូប ក្នុងឋានន្តរស័ក្តិមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ នៃក្របខណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ របស់ក្រសួងសុខាភិបាល ដូចមានរាយនាមខាងក្រោម ៖

ក្រសួងសុខាភិបាល				
ល.រ	នាម និងគោត្តនាម	ភេទ	ឋានន្តរស័ក្តិ និងថ្នាក់ចាស់	ឋានន្តរស័ក្តិ និងថ្នាក់ត្រូវដំឡើង
១	**សាផុន វឌ្ឍនៈ**	ប	ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៨	ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៧

២	**ម៉ោ ស៊ិតធី**	ប	ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ១០	ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៩
៣	**ហេង ម៉ុនគៀត**	ប	ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៨	ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៧

មាត្រា៥.- ត្រូវបានដំឡើងថ្នាក់ប្រចាំឆ្នាំជូនមន្ត្រីរាជការចំនួន ០១ រូប ក្នុងឋានន្តរស័ក្តិរមន្ត្រីនៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដូចមាននាមខាងក្រោម ៖

ល.រ	នាម និងគោត្តនាម	ភេទ	ឋានន្តរស័ក្តិ និងថ្នាក់ចាស់	ឋានន្តរស័ក្តិ និងថ្នាក់ត្រូវដំឡើង
១	**សួស សម្បត្តិ**	ប	ពីវរមន្ត្រី ថ្នាក់លេខ ៨	ទៅវរមន្ត្រី ថ្នាក់លេខ ៧

មាត្រា៦.- មន្ត្រីរាជការដែលត្រូវបានដំឡើងថ្នាក់ដូចមានឈ្មោះក្នុងមាត្រា ៤ ខាងលើ ត្រូវរក្សាទុកអតីតភាពសម្រាប់ឡើងថ្នាក់តាមវេនជ្រើសរើស និងវេនអតីតភាពដដែល។

មាត្រា៧.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ មាត្រា២ មាត្រា៣ មាត្រា៤ និងមាត្រា៥ ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា៧
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១១៧៧. អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការដំឡើងថ្នាក់មន្ត្រីរាជការ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

